UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

United Nations
Human Rights
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS

## អ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជាស្វាគមន៍ការទទួលយក របស់រាជរដ្ឋាភិបាលកម្ពុជានូវអនុសាសន៍នៃការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់(UPR)

ទីក្រុងហ្សឺណែវ ២៩ មីនា ២០១០

អ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា លោកសាស្ត្រាចារ្យ ស៊ូយ៉ា ប្រាសាទ ស៊ូបៃឌី ស្វាគមន៍ការសំរេចរបស់រាជរដ្ឋាភិបាលកម្ពុជា ទទួលយកអនុសាសន៍ ៩១ បន្ទាប់ពីការដាក់ស្នើរបស់កម្ពុជា ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នូវរបាយការណ៍ជាសកលតាមកាលកំណត់(UPR)។ អ្នករាយការណ៍ពិសេសបានមានប្រសាសន៍ថា " នេះបង្ហាញឲ្យឃើញពីការសន្យាជាសាធារណៈរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកសាងប្រព័ន្ធនីតិរដ្ឋមួយដែលដំណើរការ ដូចបានណែនាំដោយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលជាកត្តាសំខាន់មួយ ក្នុងការអភិវឌ្ឍន៍ប្រទេស"។

កម្ពុជាគឺជារដ្ឋមួយក្នុងចំណោមរដ្ឋជាសមាជិកតិចតួចបំផុត ដែលបានអនុម័តយល់ព្រមជាផ្លូវការលើគ្រប់អនុសាសន៍ទាំងអស់ ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ក្រោមយន្តការពិនិត្យរបាយការណ៍ជាសាកលតាមកាលកំណត់ របាយការណ៍សិទ្ធិមនុស្សរបស់រដ្ឋជាសមាជិកទាំងអស់ ១៩២ ត្រូវបានពិនិត្យដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលត្រូវធ្វើម្តងរៀងរាល់បួនឆ្នាំ។ យន្តការនេះផ្តល់លទ្ធភាពឲ្យរដ្ឋជាសមាជិកដទៃទៀតពិនិត្យរបាយការណ៍សិទ្ធិមនុស្សគ្នាទៅវិញទៅមក ទាំងការទទួលស្គាល់ពីការរីកចំរើន ទាំងការសំគាល់ពីវិស័យទាំងឡាយដែលត្រូវយកចិត្តទុកដាក់។

នៅក្រុមប្រឹក្សាសិទ្ធិមនុស្ស រដ្ឋជាសមាជិកនានា បានទទួលស្គាល់ការរីកចំរើនគួរឲ្យកត់សំគាល់ ដែលកម្ពុជាសំរេចបាន ដោយគិតគូរអំពីការដែលប្រទេសនេះ បានឆ្លងកាត់រយៈពេលមួយដ៏វែង បន្ទាប់ពីសង្គ្រាមបីទសវត្សរ៍មក។ ក្នុងចំណោមវិស័យឯទៀត ពួកគេបានស្វាគមន៍ការអនុម័តច្បាប់សំខាន់ៗជាច្រើន កិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងការទទួលបានសិទ្ធិខាងសុខភាព និងការអប់រំ ការលើកស្ទួយសិទ្ធិស្ត្រី និងកំណែទម្រង់ផ្សេងទៀតកំពុងដំណើរការ រាប់ទាំងកំណែទម្រង់វិស័យអប់រំកែប្រែផងដែរ។ ពួកគេបានបន្ទរសំលេងអនុសាសន៍ដោយស្ថាប័នសន្ធិសញ្ញា និងអ្នកជំនាញការឯទៀតរបស់អង្គការសហប្រជាជាតិ ក៏ដូចជាអង្គការសង្គមស៊ីវិលទាក់ទងនឹងសេចក្តីត្រូវការក្នុងការពង្រឹងក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ដើម្បីការពារសិទ្ធិខាងដីធ្លី និងលំនៅដ្ឋាននិងពង្រឹងឯករាជ្យភាព និងសមត្ថភាពនៃស្ថាប័នតុលាការ។ សារៈសំខាន់នៃការលើកកំពស់ និងការការពារសេរីភាពក្នុងការប្រជុំ និងសេរីភាពខាងការសំដែងមតិ ដែលជាកត្តាសំខាន់នៃការជជែកពិភាក្សាក្នុងដំណើរការប្រជាធិបតេយ្យ ត្រូវបានគូសបញ្ជាក់ ក៏ដូចជាសារៈសំខាន់ដែលផ្សារភ្ជាប់ទៅនឹងការពិភាក្សារវាងរដ្ឋាភិបាល និង

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

សង្គមស៊ីវិល និងសេចក្តីត្រូវការក្នុងការការពារសកម្មជនសិទ្ធិមនុស្ស។ រដ្ឋជាសមាជិកស្វាគមន៍ការចូលរួមរបស់កម្ពុជាជាមួយយន្តការសិទ្ធិមនុស្សដទៃទៀតរបស់អង្គការសហប្រជាជាតិ រាប់ទាំងអ្នករាយការណ៍ពិសេស និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សផងដែរ ។

ការសាកល្បងពិតប្រាកដនៃអនុសាសន៍ពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់(UPR) ចាប់ផ្តើមពីការអនុវត្តន៍មានប្រសិទ្ធិភាព។ ក្នុងនោះមានអនុសាសន៍ជាច្រើន បាននឹងកំពុងអនុវត្តរួចហើយ។ អ្នករាយការណ៍ពិសេសជំរុញលើកទឹកចិត្តដល់រដ្ឋាភិបាលឲ្យ "ទាក់ទាញអ្នកពាក់ព័ន្ធសំខាន់ៗ រាប់ទាំងអង្គការសង្គស៊ីវិលផងដែរឲ្យចូលរួមបន្តអនុវត្តការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់(UPR)" លោកបានមានប្រសាសន៍ទៀតថា "ខ្ញុំសង្ឃឹមរីករាយនឹងធ្វើការជាមួយរដ្ឋាភិបាល តួអង្គសង្គមស៊ីវិល ការិយាល័យ OHCHR និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ក៏ដូចជា ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីបន្តធ្វើសមាហរណកម្មអនុសាសន៍ទាំងនេះទៅក្នុងគោលនយោបាយ ច្បាប់ និង ការអនុវត្តន៍របស់ខ្លួន នៅក្នុងដំណាក់កាលបន្ទាប់នៃដំណើរការពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់ (UPR)" ៕